**សេចក្តីប្រកាសមន្ទីរអប់រំមធ្យមសិក្សា ទី ២៨**
**រឿងចេតនាសុចរិតក្នុងការគ្រប់គ្រងមន្ទីរអប់រំមធ្យមសិក្សាទី ២៨**

---

នាយកដ្ឋានចំណេះទូទៅផ្តោតជាសំខាន់លើការគ្រប់គ្រងការងារដោយ ភាពសុចរិត និងតម្លាភាពតាមគោលនយោបាយ (នាយករដ្ឋមន្ត្រីឯកឧត្តមឧត្តមសេនីយ៍ឯក**ប្រះយុទ្ធ ចាន់អូឆា**) កាលពីថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៤ ក្នុងការលើកស្ទួយការដឹកនាំប្រទេសជាតិដោយអភិបាលកិច្ចល្អ និងការការពារបង្ក្រាបនូវអំពីទុច្ចរិតនិងទង្វើខុសឆ្គងក្នុងស្ថាប័នរដ្ឋ តាមកម្រងច្បាប់ក្រមសីលធម៌ស្តីអំពីការអនុវត្តិការងារដើម្បីការពារផលប្រយោជន៍ត្រួតគ្នារបស់មន្ត្រីរាជការក្នុងមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ ឆ្នាំ ២០១៨ សៀវភៅណែនាំការអនុវត្តិការងារតាមមាត្រដ្ឋា នការអនុវត្តិការងាររបស់មន្ទីរអប់រំមធ្យមសិក្សា ទី ២៨ និងតាមសៀវភៅណែនាំការវាយតម្លៃភាពសុចរិតនិងតម្លាភាពក្នុងការអនុវត្តិការងាររបស់ស្ថាប័នរដ្ឋ (Integrity and Transparency Assessment : ITA) របស់ការិយាល័យគណៈកម្មការការពារនិងបង្ក្រាបអំពើទុច្ចរិតជាតិ (ការិយាល័យ ក.ប.ជ.) និងការិយាល័យគណៈកម្មការការពារនិងបង្ក្រាបអំពើទុច្ចរិតក្នុងស្ថាប័នរដ្ឋ (ប.ទ.)។

មន្ទីរអប់រំមធ្យមសិក្សា ទី ២៨ បានសិក្សាស្វែងយល់និងរៀបចំនូវផែនការអនុវត្តិការពារនិងបង្ក្រាបនូវអំពើទុច្ចរិត មន្ទីរអប់រំមធ្យមសិក្សា ទី ២៨ ប្រចាំឆ្នាំ ២០១៦ -២០២០ (រយៈពេល ៤ ឆ្នាំ) ដែលគ្របដណ្តប់ទាំងតម្លាភាពទាំងទំនួលខុសត្រូវ សុវត្ថិភាពពីអំពើទុច្ចរិតក្នុងការអនុវត្តិការងារ វប្បធម៌សុចរិតក្នុងអង្គភាព ភាពសុចរិតក្នុងការមន្ទីរការទំនាក់ទំនងក្នុងកន្លែងធ្វើការនិងជឿជាក់ថា ទង្វើរបស់មន្ត្រីរាជការនិងបុគ្គលិកក្រោមឱវាទគ្រប់រូបត្រូវឆ្លើយតបតាមតម្រូវការរបស់សង្គម ជាទីទុកចិត្តរបស់ប្រជាជន និងរំពឹងថាមន្ត្រីរាជការគ្រប់រូបនឹងប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរក្នុងពេលអនុវត្តិតួនាទីដែលបានទទួលខុសត្រូវរបស់ខ្លួនដើម្បីប្រើក្នុងការប្រៀបធៀបជាមួយការប្រតិបត្តិនិងការពិចារណាកែលម្អនូវទង្វើរបស់ខ្លួនឲ្យបានសមរម្យ។

ខ្ញុំសូមបង្ហាញនូវចេតនាក្នុងនាមជាអ្នកដឹកនាំគ្រប់គ្រងមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ ដែលត្រៀមខ្លួនក្នុងការលើកស្ទួយមន្ត្រីរាជការនិងបុគ្គលិកគ្រប់រូបក្នុងមន្ទីរឲ្យ មានភាពសុចរិត តម្លាភាពក្នុងការបំពេញតួនាទី ដែលមានប្រសិទ្ធិភាពនិងប្រសិទ្ធិផល ដើម្បីរក្សាបាននូវអត្ថប្រយោជន៍របស់រដ្ឋនិងផ្តល់ជូននូវភាពយុត្តិធម៌ដល់ប្រជាជនជាប្រចាំដោយសមភាព។

ខ្ញុំសូមបញ្ជាក់អះអាងថាមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ នឹងប្រកាន់ខ្ជាប់ក្នុងភាពជាស្ថាប័នរដ្ឋដែលមានតម្លាភាពនិងត្រៀមខ្លួនក្នុងការធ្វើសវនកម្មបាន ឲ្យស្របតាមទស្សនវិស័យរបស់នាយកដ្ឋានចំណេះទូទៅគឺ "ការសិក្សាថ្នាក់មូលដ្ឋានរបស់ប្រទេសថៃមានគុណភាពនិងមាត្រដ្ឋានកម្រិតសកលលោកលើមូលដ្ឋានភាពជាថៃ" ។

/ខ្ញុំ...

ខ្ញុំសូមបង្ហាញនូវចេតនាចំពោះសហការីមន្ត្រីរាជការគ្រប់រូបថា ខ្ញុំនឹងបំពេញតួនាទីក្នុងការដឹកនាំដើម្បីការពារនិងបង្ក្រាបនូវអំពើទុច្ចរិតក្នុងស្ថាប័នរដ្ឋ ដោយមនសិកា រនិងដឹងនូវទំនួលខុសត្រូវដែលមានស្រាប់ នឹងប្តេជ្ញាចិត្តក្នុងការអនុវត្តិការងារពេញសតិបញ្ញា សមត្ថភាពដោយភាពសុចរិតទៀងត្រង់ និងមានសតិយល់ដឹងនូវអ្វីដែលត្រឹមត្រូវ អ្វីដែលខុសឆ្គង អ្វីគួរធ្វើ អ្វីដែលគួរជៀសវាង ដើម្បីឲ្យការងារដែលអនុវត្តិមិនទទួលបាននូវការខូចខាត និងបង្កើតបាននូវអត្ថប្រយោជន៍ដ៏ឧត្តុង្គឧត្តម ដោយប្រកាន់យកនូវគោលការណ៍អភិបាលកិច្ចល្អក្នុងការដឹកនាំគ្រប់គ្រងនិងប្រកាន់នូវជំហរប្រឆាំងនឹងអំពើទុច្ចរិតគ្រប់ប្រភេទ ទាំងនេះដើម្បីប្រយោជន៍ដ៏ឧត្តមរបស់ប្រជាជន និងចូលរួមធ្វើនូវអំពើល្អដើម្បីព្រះមហាក្សត្ររបស់យើង។

ក្នុងនាមថ្នាក់គ្រប់គ្រងគ្រប់លំដាប់ថ្នាក់របស់មន្ទីរអប់រំមធ្យមសិក្សា ទី ២៨ សូមប្រកាសនូវចេតនាថានឹងគ្រប់គ្រងការងារដោយភាពសុចរិតតាមគោល ការណ៍អភិបាលកិច្ចល្អ មានតម្លាភាព អាចធ្វើសវនកម្មបាន ព្រមទាំងទទួលខុសត្រូវដើម្បីបង្កើតនូវទំនុកចិត្តជឿជាក់ចំពោះសង្គមថា មន្ទីរអប់រំមធ្យមសិក្សា ទី ២៨ មានចេតនាក្នុងការប្រឆាំងនឹងអំពើទុច្ចរិតគ្រប់ប្រភេទ និងប្រកាន់នូវជំហរក្នុងការធ្វើឲ្យមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ ជាស្ថាប័នរដ្ឋពណ៌សជានិរន្តរ៍ដោយអនុវត្តិ ដូចតទៅនេះ :

១. បំពេញតួនាទីគ្រប់ដំណាក់កាលតាមច្បាប់ លក្ខខន្តិកៈ និងបទបញ្ញត្តិគ្រប់យ៉ាង ខ្ជាប់ខ្ជួនរហូតដល់លើកស្ទួយឲ្យបុគ្គលិកអនុវត្តិតាមច្បាប់ លក្ខខន្តិកៈ និងបទបញ្ញត្តិដែលបានកំណត់។

២. បណ្តុះនិងបង្កើតនូវការយល់ដឹង គុណតម្លៃក្នុងការប្រឆាំងនឹងអំពើទុច្ចរិតពុករលួយ ចេះ វែកញែកឲ្យដាច់ពីគ្នា នូវប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍សមូហភាព ដើម្បីបណ្តុះនូវមនសិកា រសុចរិតនិងការពារអំពើទុច្ចរិតពុករលួយក្នុងអង្គភាព រួមទាំងមានតុល្យភាពផ្ទៃក្នុងដ៏រឹងមាំ មានប្រសិទ្ធិភាព ដែលធ្វើឲ្យបុគ្គលិកក្នុងមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ យល់ដឹងអំពីផលអាក្រក់ គ្រោះថ្នាក់នៃអំពើទុច្ចរិតពុករលួយចំពោះអង្គភាពរដ្ឋនិងប្រទេសជាតិ ដើម្បីឲ្យកើតមាននូវវប្បធម៌ការប្រឆាំងនឹងអំពើទុច្ចរិតពុករលួយ។

៣. មិនព្រមទទួលនូវអំពើទុច្ចរិតពុករលួយ និងមិនអត់ទ្រាំចំពោះអំពើទុច្ចរិតដែលបង្កឲ្យកើតមានការដាក់ទោសផ្លូវសង្គម (Social Sanction) ដែលធ្វើឲ្យបុគ្គលិកក្នុងមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ មានភាពអៀនខ្មាសឬខ្លាចក្រែងចំពោះអំពើទុច្ចរិតពុករលួយ។

៤. បណ្តុះនូវមនសិកា រដល់សិស្សានុសិស្សនៅក្នុងស្ថាប័នអប់រំក្រោមឱវាទមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ ឲ្យយល់ដឹងនូវផលអាក្រក់និងប្រឆាំងនឹងអំពើទុច្ចរិតពុករលួយ។

៥. ទិសដៅការអនុវត្តិនិងសកម្មភាពការសហការ។

៥.១ ទំនាក់ទំនងនិងសហការក្នុងការជម្រុញយុទ្ធសាស្ត្រជាតិស្តីអំពីការការពារនិងបង្ក្រាបនូវអំពើទុច្ចរិតដំណាក់កាលទី ៣ (ឆ្នាំ ២០១៧-២០២១) ។

៥.២ គ្រប់អង្គភាពនិងបុគ្គលិកក្រោមឱវាទសហការចូលរួមជាបណ្តាញការពារបង្ក្រាបនូវអំពើទុច្ចរិតក្នុងនាយកដ្ឋានចំណោះទូទៅ ជាមួយនាយកដ្ឋានថ្នាក់លើនិងមន្ទីរអប់រំថ្នាក់ខេត្ត។

៥.៣ សហការគ្នាក្នុងការសិក្សា រួបរួមចំណេះដឹងក្នុងការការពារនិងបង្ក្រាបនូវរាល់អំពើទុច្ចរិត។

/៥.៤ ចូលរួមរៀបចំ...

៥.៤ ចូលរួមផ្ដល់នូវចំណេះដឹងអំពីយុទ្ធសាស្ត្រជាតិស្ដីអំពីការការពារនិងបង្ក្រាបនូវអំពើទុច្ចរិតដំណាក់កាលទី ៣ (ឆ្នាំ ២០១៧ -២០២១) ជាពិសេសទិសដៅក្នុងការលើកស្ទួយគុណធម៌ ចរិយធម៌ដល់អ្នកគ្រប់គ្រងស្ថាប័នអប់រំ មន្ត្រីរាជការគ្រូបង្រៀន និងបុគ្គលិកអប់រំដែលស្ថិត នៅក្រោមឱវាទមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ ដែលមានការពាក់ព័ន្ធនឹងការរៀបចំការអប់រំរបស់មន្ទីរអប់រំមធ្យមសិក្សា ទី ២៨ គ្រប់កម្រិតដើម្បី បាននូវចំណេះដឹង ការយល់ដឹងនិងរួមចំណែកក្នុងការផ្សព្វផ្សាយនូវយុទ្ធនាការឲ្យយុវជន អាណាព្យាបាល និងប្រជាជនទូទៅបានចូលរួមក្នុងការរៀបចំនូវសកម្មភាពប្រឆាំងនឹងអំពើទុច្ចរិត ហើយចូលរួមជាបណ្ដាញដើម្បីការពារនិងបង្ក្រាបនូវអំពើទុច្ចរិត។

៥.៥ ចូលរួមរៀបចំផ្ដល់ នូវចំណេះដឹងទាក់ទងនឹងការឃ្លាំមើលប្រុងប្រយ័ត្ននិងពិនិត្យតាមដានដើម្បីប្រឆាំងនឹងអំពើទុច្ចរិតចំពោះបុគ្គលិកអប់រំក្នុងមូលដ្ឋានទូទាំងប្រទេស ដូចជា អ្នកគ្រប់គ្រងការអប់រំ អ្នកគ្រប់គ្រងស្ថាប័នអប់រំ និងបុគ្គលិកអប់រំដែលពាក់ព័ន្ធគ្រប់កម្រិត ដើម្បីបង្កើតនូវចំណេះដឹងនិងចូលរួមក្នុងការផ្សព្វផ្សាយនូវយុទ្ធនាការដល់យុវជន អាណាព្យាបាល និងប្រជាជនទូទៅឲ្យចូលរួមក្នុងការរៀបចំសកម្មភាពប្រឆាំងនឹងអំពើទុច្ចរិត និងចូលរួមជាបណ្ដាញដើម្បីការពារនិងបង្ក្រាបនូវអំពើទុច្ចរិត។

៥.៦ សហការគ្នាក្នុងការរៀបចំសន្ទស្សន៍វាយតម្លៃភាពសុចរិតនិងតម្លាភាពសម្រាប់អង្គភាពក្រោមឱវាទមន្ទីរអប់រំមធ្យមសិក្សា ទី ២៨ និងអនុវត្តតាមទិសដៅដែលបានកំណត់ តាមយុទ្ធសាស្ត្រជាតិស្ដីអំពីការការពារនិងបង្ក្រាបនូវអំពើទុច្ចរិត ដំណាក់ទី ៣ (ឆ្នាំ ២០១៧-២០២១)។

៥.៧ សហការគ្នាក្នុងការបង្កើតផ្លូវទំនាក់ទំនង ផ្សព្វផ្សាយ និងប្រកាស ដើម្បីគាំទ្រការដំណើរការក្នុងនាមបណ្ដាញសហការការពារនិងបង្ក្រាបនូវអំពើទុច្ចរិត។

៥.៨ ចូលរួមផ្ដល់យោបល់ ស្នើនូវទិសដៅ រួមទាំងការតាមដាននិងវាយតម្លៃការអនុវត្តការសហការទាំងនោះ។

៥.៩ សហការក្នុងការអនុវត្តការងារផ្សេងទៀតក្នុងការការពារនិងបង្ក្រាបនូវអំពើទុច្ចរិតគ្រប់ប្រភេទពេញសមត្ថភាព។

ប្រកាសឲ្យបានជ្រាបជាទូទៅ។

ប្រកាសនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៨

**ប្រធានមន្ទីរអប់រំមធ្យមសិក្សា ទី ២៨**

(**លោកឥន្ទសាសន៍ ណាសាគុល**)